RAC Ratings

របាយការណ៍វាយតម្លៃឥណទានសង
លេខ: ០០៣/២៦
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៦

បុទុម សាគរ អេនើជី ឯ.ក

ចំណាត់ថ្នាក់ឥណទាន		ព័ត៌មានសញ្ញាបណ្ណ	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khA**	ទំហំសរុប	៦០០ លានដុល្លារអាមេរិក (បើដំណាក់កាល)
		ទំហំសញ្ញាបណ្ណទី១	២០០ លានដុល្លារអាមេរិក
ទស្សនវិស័យ	**ស្ថិរភាព**	ចំនួននៃការទូទាត់	ការប្រាក់ប្រចាំខែ និងប្រាក់ដើមសរុបនៅពេលឥណប្រតិទានផុតកំណត់
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khA**	រយៈពេលឥណប្រតិទាន	១ឆ្នាំ ដល់ ៣ឆ្នាំ
		ប្រភេទ	សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធធម្មតា
		អាទិភាពនៃការទូទាត់	សញ្ញាបណ្ណលំដាប់ខ្ពស់ មិនមានទ្រព្យតម្កល់
		អត្រាគូប៉ុង	ឥណប្រតិទាន១ឆ្នាំ៖ ៧,០០%
			ឥណប្រតិទាន២ឆ្នាំ៖ ៧,២៥%
			ឥណប្រតិទាន៣ឆ្នាំ៖ ៧,៥០%

អ្នកវាយតម្លៃ៖

លោក ស៊ីសុវត្តិ ចក្រការ CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៩៩៣ ៣៣៧

លោក ជូ ដេវីត
z.david@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ៦៤៣

លោក ពឹង ធៀមហេង
p.theamheng@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ១៧៨

កញ្ញា រិន មន្នីរ័ត្ន
r.monyroth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ៤០៦

អ្នកស្រី កាឡូ សូរីតា
k.sorita@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩២ ៧៧៧

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងផ្តើមការវាយតម្លៃលទ្ធភាពសងរបស់ក្រុមហ៊ុន បុទុម សាគរ អេនើជី ឯ.ក (ដែលហៅថា «BSE» ឬ «គម្រោង») ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន (ICR) គឺ **«khA»** (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ *«សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច»*។

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរ៖ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ ទម្រង់ឥណទានឯករាជ្យរបស់ BSE វិភាគលើហានិភ័យក្នុងដំណាក់កាលសាងសង់ និងហានិភ័យប្រតិបត្តិការ។ សម្រាប់ BSE ចំណាត់ថ្នាក់ទម្រង់ឥណទានឯករាជ្យ គឺ **«khBBB»** បង្ហាញពីទម្រង់ «ហានិភ័យទាប»។

កត្តាគាំទ្រខាងក្រៅ គឺត្រូវបានបង្កើតឡើងដោយភាគីពាក់ព័ន្ធដូចជា ក្រុមហ៊ុនមេ ឬក្រុមហ៊ុន ហូលឌីង (ការគាំទ្រពីគ្រប) ឬ ដោយស្ថាប័នពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល (ការគាំទ្រពីប្រទេស)។ ក្នុងករណី BSE កត្តាគាំទ្រខាងក្រៅគឺ **«ខ្លាំង»** ដោយសារតែ Royal Group ជាម្ចាស់កម្មសិទ្ធិ BSE ១០០% ដែលអាចកៀងគរការគាំទ្រពីបណ្តាក្រុមហ៊ុនសម្ព័ន្ធ។ ដូច្នេះទម្រង់ឥណទានឯករាជ្យរបស់ BSE ត្រូវបានដំឡើង មួយកម្រិតទៅ **«khA»**។

BSE គ្រោងនឹងបោះផ្សាយ«សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ Royal Group Botum Sakor» (ដែលចាប់ពីពេលនេះតទៅនឹងហៅថា «សញ្ញាបណ្ណ») ដែលមានទំហំសរុប ៦០០លានដុល្លារអាមេរិក ដោយចែកជាបីដំណាក់កាល។ គោលបំណងនៃសញ្ញាបណ្ណនេះគឺ ប្រើសម្រាប់ហិរញ្ញប្បទានការសាងសង់ និងអភិវឌ្ឍ រោងចក្រអគ្គសនីដើរដោយឧស្ម័នធម្មជាតិដែលមានទំហំ ៩០០ មេហ្គាវ៉ាត់។ បន្ទាប់ពីបញ្ចប់ គម្រោងនេះនឹងក្លាយជាកតាលីករសំខាន់មួយក្នុងគោលនយោបាយវិស័យថាមពលរបស់ប្រទេសកម្ពុជា។

ពិន្ទុស្តារឡើងវិញគឺគាំទ្រដោយលំហូរសាច់ប្រាក់វិជ្ជមានដែលមានសម្រាប់ ការសងសេវាបំណុល និងគាំទ្រដោយកិច្ចព្រមព្រៀងទិញថាមពលដើម្បីបញ្ជាក់ថាសញ្ញាបណ្ណនឹងត្រូវសងត្រឡប់គ្រប់។ ពិន្ទុស្តារឡើងវិញគឺត្រូវប៉ាន់ស្មានក្នុងចន្លោះពី ៧៥% ទៅ១០០% (អាចបណ្តាលឱ្យមានភាពយឺតតយ៉ាវក្នុងការសងទៅម្ចាស់បំណុល) ក្នុងករណីមានការក្សោយធន ការវាយតម្លៃឥណទានសញ្ញាបណ្ណគឺ **«khA»** (ចំណាត់ថ្នាក់ជាតិ) មានកម្រិតដូចចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ(ត)

សញ្ញាបណ្ណទាំងនេះនឹងត្រូវពឹងថាបោះផ្សាយលើ Cambodia Securities Dealing Platform (CSD Platform) ដែលមានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា។

ទស្សនវិស័យ

ជាទូទៅ គម្រោងហិរញ្ញវត្ថុមិនមានកំណត់ត្រាសម្រាប់ធ្វើការព្យាករណ៍ទេ។ យើងអាចត្រឹមតែពឹងផ្អែកលើការព្យាករណ៍ប្រាក់ចំណូល និង លំហូរសាច់ប្រាក់របស់ BSE ដែលសម-ហេតុផលសម្រាប់យើង។ ដូច្នេះទស្សនវិស័យដំបូងគឺ **«ស្ថិរភាព»** ដែលអាចប្រែប្រួលទៅតាម វឌ្ឍនភាពនៃការសាងសង់ និង ប្រតិបត្តិការតាមការពឹងទុក។

តាមទស្សនៈរបស់យើង ហានិភ័យចម្បងគឺស្ថិតនៅក្នុងតម្រូវការនៃការផ្តល់ហិរញ្ញប្បទានឡើងវិញរបស់គម្រោង។ ជាការពិត ការបោះផ្សាយមូលបត្របំណុល ២០០ លានដុល្លារ-អាមេរិកនាពេលបច្ចុប្បន្ននេះ មិនគ្រប់គ្រាន់សម្រាប់ចំណាយលើការសាងសង់ដែលបានប៉ាន់ប្រមាណថាមានចំនួន ១.១៩៥,៣ លានដុល្លារអាមេរិកនោះទេ។ ការផ្តល់ហិរញ្ញប្ប-ទានឡើងវិញគួរតែអាចធ្វើទៅបាន ប៉ុន្តែនៅតែអាស្រ័យលើបរិយាកាសសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងទីផ្សារពិភពលោក។

សេចក្តីសង្ខេបអំពី បុទុម សាគរ អេនើជី ឯ.ក

ទិដ្ឋភាពទូទៅ

BSE គឺជាក្រុមហ៊ុនមានគោលបំណងពិសេសដែលបង្កើតឡើង (SPV) ដើម្បីផលិតថាមពលអគ្គិសនីដើរដោយឧស្ម័នធម្មជាតិដែលមានទំហំ ៩០០ មេហ្គាវ៉ាត់ ស្ថិតនៅក្នុងខេត្ត-កោះកុងនៃព្រះរាជាណាចក្រកម្ពុជា (ដែលហៅថា «គម្រោង») ។ គម្រោងនេះជានាគាំទ្រដោយ Royal Group Investment company Limited. («RGI» ឬ «ក្រុមហ៊ុន-ឧបត្ថម្ភធន») ដែលជាកម្មសិទ្ធិរបស់*អ្នកឧកញ៉ា គិត ម៉ង* ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនក្នុងស្រុក Royal Group។ BSE នឹងមានសកម្មភាពចម្បងក្នុងការផលិតថាមពល អគ្គិសនី។ ការវិភាគនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ BSE គឺត្រូវបានប្រើវិធីសាស្ត្រក្នុងការវិភាគសម្រាប់គម្រោងហិរញ្ញវត្ថុរបស់ RAC («វិធីសាស្ត្រ») ។

នៅក្នុងវិធីសាស្ត្រ ទម្រង់ឥណទានឯករាជ្យរបស់គម្រោងមួយត្រូវបានបែងចែកជាពីរដំណាក់កាល គឺ៖ ដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិការ។ ហានិភ័យរបស់ដំណាក់កាលសាងសង់ គឺការដែលមិនអាចបញ្ចប់ការសាងសង់ឆន្ទាសម្ព័ន្ធរបស់គម្រោង។ រីឯដំណាក់កាលប្រតិបត្តិការវិញ ហានិភ័យចម្បងគឺការមិនអាចសម្រេចបាននូវលទ្ធ-ផលប្រតិបត្តិការដែលពឹងទុក នាំឱ្យប៉ះពាល់ដល់សមត្ថភាពក្នុងការសងបំណុល។

កិច្ចសន្យាចម្បងមានលក្ខណៈសមស្របសម្រាប់គម្រោងហិរញ្ញវត្ថុ ដែលមានទ្រព្យសកម្មរយៈពេលវែងសម្រាប់បង្កើតបាននូវស្ថិរភាពលំហូរសាច់ប្រាក់ដែលអាចទ្រទ្រង់អានុភាព ដ៏សំខាន់។ ក្នុងស្ថានភាពបច្ចុប្បន្ន កិច្ចសន្យាជួលដី គឺមានរយៈពេល ៥០ឆ្នាំដោយ ការផ្តល់តាមរយៈ «ការរួមចំណែកជាទ្រព្យ »។ កិច្ចព្រមព្រៀលើការផ្តត់ផ្តង់ចុងក្រោយត្រូវបាន ចុះហត្ថលេខា នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥។ ដោយគិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៦ ការសាងសង់បានរួចរាល់ ៣៥%។ គម្រោងនេះត្រូវបានចាត់ទុកជា Qualification Investment Project (QIP) ដែលបានការអនុម័តក្នុងខែមេសា ឆ្នាំ២០២៥។ អាជ្ញាបណ្ណនាំចូល និងស្តុកទុកឧស្ម័នធម្មជាតិត្រូវបានផ្តល់ឱ្យក្នុងឆ្នាំ២០២៥។

ទន្ទឹមនឹងនេះ ហានិភ័យដំណាក់កាលប្រតិបត្តិការត្រូវបានកាត់បន្ថយបន្ថែមទៀតដោយសារមានការធានារបស់ រាជរដ្ឋាភិបាលកម្ពុជា និងការធានារ៉ាប់រងប្រតិបត្តិការដែលគាំទ្រ ដោយសំណងរូបិយវត្ថុ។ ការព្យាករណ៍ហិរញ្ញវត្ថុត្រូវបានគាំទ្រដោយការពឹងទុកនៃប្រតិបត្តិការ (កិច្ចសន្យាប្រតិបត្តិការ និងការថែទាំ «O&M» នឹងត្រូវធ្វើឡើងតាមរយៈដំណើរ ការដេញថ្លៃ) ដែលមានភាពមិនច្បាស់លាស់តិចតួច។ សញ្ញាបណ្ណមានអត្រាគូប៉ុងថេរគឺ ៧,០០% (សម្រាប់សញ្ញាបណ្ណដែលមានឥណប្រតិទាន ១ឆ្នាំ) ៧,២៥%(សម្រាប់សញ្ញាបណ្ណដែលមានឥណប្រតិទាន ២ឆ្នាំ) និង ៧,៥០%(សម្រាប់សញ្ញាបណ្ណដែលមានឥណប្រតិទាន ៣ឆ្នាំ)។

ការប្រតិបត្តិ

បច្ចេកវិទ្យានិងដំណើរការនានាគឺមានភាពចាស់ទុំសម្រាប់គម្រោងរោងចក្រអគ្គសនីដើរដោយឧស្ម័នធម្មជាតិ និងមានកម្រិតហានិភ័យមធ្យម។ ម្ចាស់គម្រោងមានបទពិសោធន៍ យ៉ាងច្រើនក្នុងការអភិវឌ្ឍ ការផ្តល់ហិរញ្ញប្បទាន និងការសាងសង់រោងចក្រអគ្គិសនី ដូចជាវាអគ្គិសនីសេសានក្រោម ២ (៤០០មេហ្គាវ៉ាត់) និង រោងចក្រអគ្គិសនីដើរដោយ ថាមពលព្រះអាទិត្យ (២០០មេហ្គាវ៉ាត់) ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលសាងសង់។ ចំពោះផ្នែកចំណូល កិច្ចព្រមព្រៀងទិញលក់ថាមពល (PPA) ជាមួយ អគ្គិសនី-កម្ពុជា (EDC) ជានានូវតម្លាភាព និងស្ថិរភាព ហើយត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា។ រីឯផ្នែកចំណាយ ភាពមិនច្បាស់លាស់ចម្បងគឺថ្លៃដើមនៃកិច្ចសន្យាប្រតិបត្តិការ និង ការថែទាំ (O&M) ដែលនឹងបញ្ចាក់ក្នុងដំណាក់កាលប្រតិបត្តិការគម្រោង។

សម្គាល់៖ របាយការណ៍វាយតម្លៃលទ្ធភាពសងនេះគឺសម្រាប់សញ្ញាបណ្ណទីមួយ ដែលមានទំហំ ២០០លានដុល្លារអាមេរិក។ សញ្ញាបណ្ណបន្តបន្ទាប់ទៀតអាស្រ័យលើ ខ និង លក្ខខណ្ឌនៃសញ្ញាបណ្ណនោះដែលមិនទាន់ត្រូវបានចេញផ្សាយនៅឡើយ។ ដូច្នេះសញ្ញាបណ្ណបន្តបន្ទាប់ស្ថិតនៅក្រៅវិសាលភាពនៃរបាយការណ៍នេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**		
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច អំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

កំណត់សម្គាល់៖

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្សៀងផ្គាត់ដោយឯកភាវូទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវឬស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះបង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវឬស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការឆ្វេងប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website